# ឯកសារពិស្តារ

## ម៉ូឌុល ១

# វិមជ្ឈការ






# វិបត្តិការ

## មាតិកា

១- អ្វីទៅជាវិមជ្ឈការ? ..... ៣
២- ប្រភេទផ្សេងៗនៃវិមជ្ឈការ ..... ៣
២.១ វិមជ្ឈការនយោបាយ ..... ៤
២.២ វិមជ្ឈការរដ្ឋបាល ..... ៥
២.៣ វិមជ្ឈការហិរញ្ញវត្ថុ ..... ៦
២.៤ វិមជ្ឈការសេដ្ឋកិច្ច ..... ៦

## ១. អ្វីទៅជាវិមជ្ឈការ?

វិមជ្ឈការ គឺជាការផ្ទេរ **អំណាច** និង **ការទទួលខុសត្រូវ** ចំពោះមុខងារសាធារណៈ ពីសំណាក់រដ្ឋាភិបាលកណ្តាល/ជាតិ ទៅដល់រដ្ឋាភិបាលមូលដ្ឋាន ឬស្ថាប័នរដ្ឋាភិបាល ឯករាជ្យចំរុះមួយ ឬក៏ទៅដល់វិស័យ ឯកជន។

- ជាធម្មតា វិមជ្ឈការ គឺសំដៅទៅលើ **ការផ្ទេរអំណាច** ពីរដ្ឋាភិបាលថ្នាក់កណ្តាល/ជាតិ ទៅថ្នាក់ក្រោមនៅ ក្នុងឋានានុក្រម នយោបាយ រដ្ឋបាល និងដែនដីមួយ។
- ពាក្យថា វិមជ្ឈការ ត្រូវបានគេប្រើដើម្បីគ្របដណ្តប់ទៅលើ**ការផ្ទេរ**នៃ "**អំណាចកណ្តាលនៃការធ្វើសេចក្តីសម្រេចចិត្ត**" ពីរដ្ឋាភិបាលថ្នាក់កណ្តាលទៅរដ្ឋាភិបាលថ្នាក់ខេត្ត ក្រុង ឬថ្នាក់មូលដ្ឋាន។
- វិមជ្ឈការ គឺជាមធ្យោបាយដើម្បីអនុញ្ញាតឱ្យមាន **ការចូលរួមពីប្រជាជន** និងរដ្ឋាភិបាលថ្នាក់មូលដ្ឋាន។

**វិមជ្ឈការ** (**ក្រសួងមហាផ្ទៃ**)[1]: វិមជ្ឈការមានន័យថា រាជរដ្ឋាភិបាល **ប្រគល់នូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច ការទទួលខុសត្រូវ និងធនធាន** (ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក) ឱ្យទៅប្រឹក្សានៅថ្នាក់ក្រោមជាតិ ដូចជាក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ/សង្កាត់ ដើម្បីឆ្លើយតប ទៅនឹងតម្រូវការរបស់ពលរដ្ឋមូលដ្ឋាន។

ឧ. រាជរដ្ឋាភិបាលបានផ្ទេរថវិកាចំនួន ៤០ លានរៀល សម្រាប់ជាថវិការបស់រដ្ឋបាលស្រុកមួយ ក្នុងគោលដៅនៃការអភិវឌ្ឍ។ ក្រុមប្រឹក្សាស្រុកនេះមានភាពជាម្ចាស់ក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ថវិកានេះដើម្បី ឆ្លើយតបទៅនឹងតម្រូវការអាទិភាពរបស់ស្រុកដោយផ្អែកតាមកម្មវិធីវិនិយោគ និងផែនការអភិវឌ្ឍន៍ស្រុកដែល បានអនុម័តដោយក្រុមប្រឹក្សា ដូចជាសម្រាប់ជីកអណ្តូងទឹកស្អាត ជួសជុលផ្លូវលំ និងផ្សព្វផ្សាយអំពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនៅក្នុងសហគមន៍តាមតម្រូវការរបស់ប្រជាពលរដ្ឋជាដើម។

## ២. ប្រភេទផ្សេងៗនៃវិមជ្ឈការ

១.វិមជ្ឈការនយោបាយ : ស្វយ័ត ប្រជាធិបតេយ្យភាវូបនីយកម្ម ការបោះឆ្នោត

[1] NCDD, 2009, *Manual for basic principles in sub national administration, p.3*

២.វិមជ្ឈការរដ្ឋបាល : ប្រតិភូកម្ម (Delegation) វិសហមជ្ឈការ (Deconcentration) និង ការផ្ទេរសិទ្ធិទាំងស្រុង/វិមជ្ឈការពេញលេញ (Devolution)

៣.វិមជ្ឈការហិរញ្ញវត្ថុៈ ការរកប្រាក់ចំណូល/ទុនចូលរួមប្រាក់ចំណូល និងការចំណាយ

៤.វិមជ្ឈការសេដ្ឋកិច្ច : អនិយ័តកម្ម(ការបន្ធូរបន្ថយផ្លូវច្បាប់) (Deregulation) ឯកជនភាវូបនីយកម្ម (Privatization) ឬ សារជីវកម្មភាវូបនីយកម្ម (Corporatization)

## ២.១ វិមជ្ឈការនយោបាយ

### និយមន័យ

ជាធម្មតា វិមជ្ឈការនយោបាយ សំដៅចំពោះស្ថានភាពទាំងឡាយណាដែលផ្នែកខ្លះនៃអំណាចនយោបាយ និង អាជ្ញាធរ ត្រូវបានផ្ទេរជូនទៅកម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិ។ ព្រឹត្តិការណ៍ជាក់ស្តែងបំផុតនៃវិមជ្ឈការ ប្រភេទនេះ គឺជាទម្រង់នៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវបានបោះឆ្នោតជ្រើសរើស និងពង្រឹងភាពអង់អាចជូនដោយរាប់ចាប់ ពីក្រុមប្រឹក្សាកម្រិតថ្នាក់ឃុំ រហូតដល់ថ្នាក់ខេត្ត។[2]

### ហេតុផល

ហេតុផលនៅពីក្រោយវិមជ្ឈការនយោបាយ គឺប្រជាពលរដ្ឋ ឬអ្នកតំណាងរបស់គេ គួរមានអំណាច បន្ថែមទៀតក្នុងការសម្រេចចិត្តជាសាធារណៈ។ ការសម្រេចចិត្តទាំងឡាយណាដែលត្រូវបានធ្វើឡើងដោយមាន ការចូលរួមកាន់តែច្រើន នឹងនាំឱ្យទទួលបានការផ្តល់ព័ត៌មានកាន់តែប្រសើរ និងកាន់តែស្របទៅនឹង ផលប្រយោជន៍ ដោយឡែកពីគ្នារបស់ប្រជាពលរដ្ឋនៅក្នុងសង្គម បើធៀបទៅនឹងការសម្រេចចិត្តដែលធ្វើឡើង ដោយអាជ្ញាធរ ថ្នាក់ជាតិ។ វាក៏នឹងនាំឱ្យមានសេវាសាធារណៈដែលប្រកបដោយប្រសិទ្ធផល និងប្រសិទ្ធភាពផងដែរ។ ដូច្នេះ វិមជ្ឈការនយោបាយ គឺនិយាយអំពីការបង្កើតឱ្យមាននូវឱកាសសម្រាប់រដ្ឋបាលថ្នាក់មូលដ្ឋាន ដើម្បីឈ្វេងយល់ និងអនុវត្តទៅតាមតម្រូវការ និងចំណង់ចំណូលចិត្តរបស់ប្រជាជន។

### ដើម្បីសម្រេចឱ្យបាននូវវិមជ្ឈការនយោបាយត្រូវពិចារណាទៅលើចំណុចទាំងអស់ខាងក្រោម :

- កំណែទម្រង់រដ្ឋធម្មនុញ្ញ ឬកំណែទម្រង់ច្បាប់ ដើម្បីឱ្យស្របទៅនឹងខ្លឹមសារវិមជ្ឈការ
- ការបង្កើតគណៈបក្សនយោបាយឱ្យបានច្រើន
- ពង្រឹងអំណាចនីតិបញ្ញត្តិ

[2] EU, 2007, គាំទ្រវិមជ្ឈការ និងអភិបាលកិច្ចមូលដ្ឋាន នៅក្នុងប្រទេសដែលមានការអភិវឌ្ឍតិច

- បង្កើតអង្គភាពនយោបាយថ្នាក់មូលដ្ឋាន
- លើកទឹកចិត្តឱ្យមានក្រុមដែលបម្រើការងារឱ្យប្រយោជន៍សាធារណៈ ប្រកបដោយប្រសិទ្ធភាព

## ២.២ វិមជ្ឈការរដ្ឋបាល

**និយមន័យ**

វិមជ្ឈការរដ្ឋបាល សំដៅចំពោះការផ្ទេរទាំងស្រុង ឬផ្នែកណាមួយ នៃសិទ្ធិអំណាចក្នុងការសម្រេចចិត្ត ធនធាន និងការទទួលខុសត្រូវ សម្រាប់ការផ្តល់សេវាសាធារណៈមួយចំនួន ដែលត្រូវបានជ្រើសរើសពីរដ្ឋាភិបាលកណ្តាល ទៅកាន់រដ្ឋបាល ភ្នាក់ងារ និងការិយាល័យរបស់ភ្នាក់ងារពាក់ព័ន្ធរបស់រដ្ឋាភិបាលកណ្តាល ដែលមានកម្រិតទាបជាង ។

**ប្រភេទនៃវិមជ្ឈការរដ្ឋបាល**

**វិសហមជ្ឈការ :** វិសហមជ្ឈការ តែងត្រូវបានចាត់ទុកថា ជាទម្រង់មួយខ្សោយបំផុតរបស់វិមជ្ឈការ ហើយប្រព័ន្ធនេះតែងត្រូវបានប្រើប្រាស់ញឹកញាប់បំផុត នៅក្នុងរដ្ឋដែលប្រកាន់ទុកអំណាចនៅថ្នាក់កណ្តាល ។ វិសហមជ្ឈការ គឺជាការផ្ទេរអំណាចទៅឱ្យអង្គភាពរដ្ឋបាលមួយរបស់រដ្ឋាភិបាលថ្នាក់កណ្តាល ដែលជាទូទៅគឺជា ការិយាល័យជំនាញនៅក្នុងវិស័យ ។ ជាមួយនឹងប្រព័ន្ធវិសហមជ្ឈការនេះ មន្ត្រីក្នុងមូលដ្ឋាន មិនត្រូវបានបោះឆ្នោតជ្រើសរើសនោះទេ ។

**ប្រតិភូកម្ម :** ប្រតិភូកម្ម គឺជាទម្រង់មួយដែលមានលក្ខណៈកាន់តែទូលំទូលាយនៃវិមជ្ឈការ ។ តាមរយៈការធ្វើប្រតិភូកម្ម រដ្ឋាភិបាលកណ្តាលផ្ទេរការទទួលខុសត្រូវ សម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត និងរដ្ឋបាលនៃមុខងារសាធារណៈទៅឱ្យអង្គការពាក់កណ្តាលស្វ័យភាព ដែលអង្គការនេះពុំស្ថិតក្រោមការគ្រប់គ្រងទាំងស្រុង របស់រដ្ឋាភិបាលកណ្តាល ប៉ុន្តែទីបំផុតត្រូវផ្តល់គណនេយ្យភាពចំពោះរដ្ឋាភិបាលកណ្តាល ។ ជាមួយនឹងប្រតិភូកម្ម មន្ត្រីក្នុងមូលដ្ឋានមិនត្រូវបានបោះឆ្នោតជ្រើសរើសនោះទេ ។ រដ្ឋាភិបាលធ្វើប្រតិភូកម្មទៅលើការទទួលខុសត្រូវ នៅពេលដែលគេបង្កើតឱ្យមាននូវសហគ្រាស ឬសាជីវកម្មសាធារណៈ អាជ្ញាធរផ្គត់ផ្គង់ទឹកជម្រក អាជ្ញាធរដឹកជញ្ជូន ស្រុកដែលផ្តល់សេវាកម្មពិសេស ស្រុកដែលមានពាក់កណ្តាលស្វ័យភាពក្នុងការគ្រប់គ្រងសាលារៀន សាជីវកម្មអភិវឌ្ឍក្នុងតំបន់ ឬអង្គភាពពិសេសសម្រាប់អនុវត្តគម្រោង ។

**ការផ្ទេរសិទ្ធិទាំងស្រុង:** គឺជាទម្រង់មួយដ៏ខ្លាំងក្លាបំផុតនៃវិមជ្ឈការរដ្ឋបាល ។ នៅពេលដែលរដ្ឋាភិបាលផ្ទេរមុខងារ គឺគេផ្ទេរសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្ត ហិរញ្ញវត្ថុ និងការគ្រប់គ្រងទៅឱ្យអង្គភាពដែលសឹងតែមានស្វ័យភាពរបស់រដ្ឋាភិបាលមូលដ្ឋាន ដែលមានលក្ខណៈជាអង្គភាពដាច់ដោយឡែកស្របច្បាប់ ។

ជាទូទៅការផ្ទេរសិទ្ធិទាំងស្រុងតែងផ្ទេរការទទួលខុសត្រូវផ្នែកសេវាកម្ម ទៅឱ្យបណ្ដារាជធានីទាំងឡាយណាដែលធ្វើការបោះឆ្នោតជ្រើសរើសអភិបាលរាជធានី និងក្រុមប្រឹក្សារបស់គេ ស្វែងរកចំណូលដោយខ្លួនឯង និងមានអាជ្ញាធរឯករាជ្យដើម្បីធ្វើសេចក្ដីសម្រេចចិត្តលើផ្នែកវិនិយោគ។ នៅក្នុងប្រព័ន្ធផ្ទេរសិទ្ធិទាំងស្រុងរដ្ឋបាល មូលដ្ឋានមានព្រំប្រទល់ភូមិសាស្ត្រច្បាស់លាស់ និងត្រូវបានទទួលស្គាល់ដោយច្បាប់ ដែលគេអាចអនុវត្ត សិទ្ធិអំណាច និងបំពេញមុខងារសាធារណៈរបស់គេនៅក្នុងព្រំដែនភូមិសាស្ត្រនោះ។

**ហេតុផល**

ប្រសិនបើរដ្ឋបាលមូលដ្ឋាន និងអង្គភាពឯកជន ត្រូវអនុវត្តមុខងារដែលបានធ្វើវិមជ្ឈការប្រកបដោយ ប្រសិទ្ធ ភាព។ ដើម្បីសម្រេចការងារនេះ ចាំបាច់តម្រូវឱ្យប្រជាជន( មន្ត្រីបំពេញភារ កិច្ច) មានសមត្ថភាពចាំបាច់ (ចំណេះធ្វើ) ដើម្បីអនុវត្តនូវមុខងារដែលត្រូវបានធ្វើវិមជ្ឈការទាំងនោះ។ ទម្រង់បែបនេះ នឹងត្រូវពាក់ព័ន្ធទៅនឹងកំណែទម្រង់សេវាកម្មស៊ីវិល។

## ២.៣ វិមជ្ឈការហិរញ្ញវត្ថុ

**និយមន័យ**

វិមជ្ឈការហិរញ្ញវត្ថុ ពាក់ព័ន្ធទៅនឹងកម្រិតនៃការបែងចែកធនធានទៅដល់រដ្ឋបាលមូលដ្ឋាន ដែលអនុញ្ញាតិឱ្យរដ្ឋាភិបាលនេះ អនុវត្តមុខងារមួយចំនួនដែលត្រូវបានធ្វើវិមជ្ឈការ។ ច្បាប់របស់វិមជ្ឈការសារពើពន្ធធ្វើនិយ័តកម្មទៅលើវិស័យចំនួនបួន : (i) កិច្ចការចំណាយ (ii) កិច្ចការចំណូល (iii) ការផ្ទេរអន្តររដ្ឋាភិបាល និង (iv) ការខ្ចីធនធាននៅថ្នាក់ក្រោមជាតិ។

**មូលហេតុ**

ប្រសិនបើរដ្ឋាភិបាលថ្នាក់មូលដ្ឋាន និងអង្គភាពឯកជន ត្រូវអនុវត្តមុខងារដែលត្រូវបានធ្វើវិមជ្ឈការប្រកបដោយប្រសិទ្ធភាព និងដើម្បីឱ្យអាជ្ញាធរអាចធ្វើការសម្រេចចិត្តអំពីការចំណាយបាន គេត្រូវមានកម្រិតចំណូលមួយគ្រប់គ្រាន់ (មិនចំពោះថាកម្រិតចំណូលនោះទទួលបានពីក្នុងមូលដ្ឋាន ឬត្រូវបានផ្ទេរពីរដ្ឋាភិបាលកណ្ដាលនោះទេ)។

## ២.៤ វិមជ្ឈការសេដ្ឋកិច្ច

**និយមន័យ**

វិមជ្ឈការសេដ្ឋកិច្ច ឬវិមជ្ឈការទីផ្សារ គឺជាការផ្ទេរនូវមុខងារដែលបំពេញផ្ដាច់មុខដោយរដ្ឋាភិបាលទៅឱ្យវិស័យឯកជន។

**មូលហេតុ**

វិមជ្ឈការប្រភេទនេះ លើកកម្ពស់ការចូលរួមពីមុខជំនួញនានា ក្រុមសហគមន៍ សហករណ៍ សមាគមស្ម័គ្រចិត្ត ឯកជន និងអង្គការមិនមែនរដ្ឋាភិបាលដទៃទៀត ។

## ប្រភេទនៃវិមជ្ឈការសេដ្ឋកិច្ច

**ឯកជនភាវូបនីយកម្ម** អាចស្ថិតក្រោមវិសាលភាព ដោយគិតចាប់ពីការផ្តល់ទំនិញ និងសេវាកម្មទាំងស្រុងទៅឱ្យប្រតិបត្តិការដោយសេរីរបស់ទីផ្សាររហូតដល់ "ភាពជាដៃគូសាធារណៈ- ឯកជន" ដែលរដ្ឋាភិបាល និងវិស័យឯកជនសហប្រតិបត្តិការ ដើម្បីផ្តល់សេវាកម្ម ឬហេដ្ឋារចនាសម្ព័ន្ធ។

**អនិយ័តកម្ម**(ការបន្ធូរបន្ថយផ្លូវច្បាប់) កាត់ បន្ថយឧបសគ្គផ្នែកច្បាប់ទៅលើវិស័យឯកជនក្នុងការផ្តល់សេវាកម្ម ដែលកន្លងមកផ្តាច់មុខដោយរដ្ឋាភិបាល។ រយៈ ពេលប៉ុន្មានឆ្នាំកន្លងមកនេះ ឯកជនភាវូបនីយកម្ម និងអនិយ័តកម្ម បានក្លាយទៅជាជម្រើសដោយឡែកកាន់តែ គួរឱ្យទាក់ទាញចំពោះរដ្ឋាភិបាលនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ។ រដ្ឋបាលមូលដ្ឋានក៏កំពុងតែធ្វើ ឯកជនភាវូប នីយកម្មតាមរយៈការចុះកិច្ចសន្យាទៅលើការងារផ្តល់សេវាកម្ម ឬរដ្ឋបាល។

**ឧទាហរណ៍ :** ការផ្តល់បច្ចេកទេសគាំទ្រដល់រដ្ឋបាលនៅថ្នាក់ក្រោមក្នុងវិស័យគ្រប់គ្រងទឹកធ្វើតាមរយៈក្រុមហ៊ុន ឯកជនជំនួសក្រសួងធនធានទឹកថ្នាក់ជាតិដែលនេះជាទម្រង់នៃអនិយ័តកម្ម ។